# អង្គការសាមគ្គី កំពង់ចាម

# របាយការណ៍សកម្មភាព
# ប្រចាំឆ្នាំ២០១៦

Deykraham village, Mean commune, Prey Chhor district, Kg Cham province, Tel: 017 820 190, E-mail: samakyngo@yahoo.com

**មាតិកា** **ទំព័រ**


១. ប្រវត្តិ និងស្ថានភាពទូទៅ ..... 1
២. ផែនការសកម្មភាព និងលទ្ធផលសំរេចបានក្នុងឆ្នាំ២០១៥ ..... 2
លទ្ធផលរំពឹងទុកទី១៖ ..... 2
១.១. សិក្ខាសាលាឆ្លុះបញ្ចាំងពីលទ្ធផលអនុវត្តរបស់កសិករទាំងចាស់ទាំងថ្មី៣៥នាក់ ..... 3
១.២. បន្តតាមដាន និងកែលំអការអនុវត្តរបស់កសិករគំរូដែលមានស្រាប់ ..... 3
១.៣. បង្ហាត់បង្ហាញផ្ទាល់ដល់កសិករពង្រីក ដែលមានស្រាប់ ..... 3
លទ្ធផលរំពឹងទុកទី២៖ ..... 3
២.១. ប្រជុំឆ្លុះបញ្ចាំងជាមួយកសិករចិញ្ចឹមត្រី ..... 4
២.២.តាមដាន និងគាំទ្រគណៈកម្មការចុះល្បាតបទល្មើសនេសាទ ..... 4
២.៣. ប្រជុំគណៈកម្មការសហគមន៍នេសាទប្រចាំឆមាស ..... 4
លទ្ធផលរំពឹងទុកទី៣៖ ..... 5
៣.១.ប្រជុំឆ្លុះបញ្ចាំងពីដំណើរការប្រើប្រាស់ទឹករវាងគណៈកម្មការតាកុត និងប្រធានក្រុមស្រែប្រាំង ..... 6
៣.២.ប្រជុំគណៈកម្មការស្រះតាពេញ ទំនប់កន្លែងចក និងទំនប់ថ្មដំរីប្រចាំឆមាស ..... 6
៣.៣.ប្រជុំក្រុមអណ្តូងបន្លែ និងស្រែប្រាំង(អូរសង្កែ កេះ និងដីក្រហម ..... 6
លទ្ធផលរំពឹងទុកទី៤៖ ..... 6
៤.១.ប្រជុំតំណាងក្រុម ជនបង្គោលត្រួតពិនិត្យឡើងវិញពីដំណើរការក្រុមតាមភូមិ ..... 7
៤.២.ប្រជុំត្រួតពិនិត្យ និងប្រមូលទុនតាមភូមិ ..... 7
លទ្ធផលរំពឹងទុកទី៥៖ ..... 7
៥.១.បណ្តុះបណ្តាលតំណាងក្លឹបកុមារពីគោលគំនិតនៃភាពជាដឹកនាំ ការងារក្រុម ការអភិវឌ្ឍសហគមន៍ ..... 7
៥.២.ប្រជុំតំណាងក្លឹបកុមារតាមដានពីដំណើរការ និងបញ្ហាកុមារ ..... 7
៥.៣.កម្មវិធីថ្ងៃប្រឌិតរូបភាព និងប្រលងគំនូរមុនប្រមូលសារកុមារ ..... 8
៥.៤. ប្រជុំជនបង្គោលធ្វើផែនការប្រមូលសារកុមារ ..... 8
៥.៥.កម្មវិធីប្រមូលសារកុមារ១ឆ្នាំ២ដងនិងបញ្ជ្រាបកម្មវិធីកុមារ ..... 8
៥.៦.ថតរូបបច្ចុប្បន្នភាព និងករណីសិក្សា ..... 8
៥.៧.តំណាងក្លឹបចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំលើបញ្ហាកុមារ និងការអប់រំ ..... 8
៥.៨. កម្មវិធីជប់លៀងលាកុមារគូសារ ..... 9
៥.៩. ថតវីដេអូស្តីពីការរីកចំរើនរបស់កុមារគាំពារ និងជំរាបលាកុមារចុងក្រោយ(Goodbye Video) ..... 9
១១១៧-A1.របាយការណ៍CNL និង PRO ..... 9
១១១៧-A2.សិក្ខាសាលាកម្មវិធីគាំពារកុមាររបស់បុគ្គលិក១ឆ្នាំ២ដង: ..... 9
ការងារអប់រំ: ..... 9

លទ្ធផលរំពឹងទុកទី៦៖ ..... 10
៦.១. ការចូលរួមប្រជុំជាមួយបណ្ដាញ អង្គការសង្គមស៊ីវិលក្នុងនិងក្រៅតំបន់ ..... 10
៦.២.ការអភិវឌ្ឍសមត្ថភាពបុគ្គលិកអង្គការសាមគ្គី ..... 10
៦.៣. ត្រួតពិនិត្យវាយតម្លៃបញ្ចប់គម្រោង ..... 10
៦.៤.សិក្ខាសាលាចែករំលែករបាយការណ៍ឆ្នាំ២០១៥ និងផែនការឆ្នាំ២០១៦ដល់អ្នកពាក់ព័ន្ធ ..... 10
៦.៥. ការត្រួតពិនិត្យយ៉ាងទូលំទូលាយ/ដំណើរការការឆ្លុះបញ្ចាំងនិងត្រួតពិនិត្យតាមបែបចូលរួម ..... 10
៣. ការផ្លាស់ប្តូរសំខាន់ៗ ..... 11
៤. បញ្ហាប្រឈម ឬ ឧបសគ្គៈ ..... 11
៥. ការគ្រប់គ្រងធនធានមនុស្សនៅក្នុងអង្គការ ..... 11
៦. ករណីសិក្សាពីការផ្លាស់ប្តូរ ..... 12
៧. ការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ ..... 16
៨. ការគ្រប់គ្រងផ្នែកគាំពារកុមារ ..... 16
៩. សេចក្តីសន្និដ្ឋាន ..... 16

# ១. ប្រវត្តិ និងស្ថានភាពទូទៅ

អង្គការសាមគ្គីគឺជាអង្គការមិនមែន(ក្រៅ)រដ្ឋាភិបាលបានចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃលេខ៣៥១ស.ជ.ណ ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០១។ អង្គការសាមគ្គី ធ្វើការដើម្បីរួមចំណែកកាត់បន្ថយទុក្ខលំបាកជនងាយរងគ្រោះ (ទុរគតជន អ្នកផ្ទុក ជនពិការ កុមារកំព្រា ពលកម្មកុមារ ជនជាតិដើមភាគតិច...) និងអ្នកបាត់បង់ឱកាស តាមរយៈការបង្កើនចំណេះដឹង និងការអភិវឌ្ឍន៍ធនធានមនុស្សនៅនឹងកន្លែង។ អង្គការសាមគ្គីមានទីស្នាក់ការក្នុងភូមិដីក្រហម ឃុំមៀន ស្រុកព្រៃឈរ ដែលមានចំងាយពីក្រុងកំពង់ចាមប្រមាណ២៧គីឡូម៉ែត្រ។ អង្គការសាមគ្គីអនុវត្តន៍ការងារផ្តោតលើកម្មវិធីគាំពារកុមារ ជនពិការ សិទ្ធិស្ត្រី សិទ្ធិទទួលបានចំណីអាហារ អប់រំ អភិរក្សធនធានធម្មជាតិ អភិបាលកិច្ចល្អ និងប្រជាធិបតេយ្យ។

## ទស្សនវិស័យ:

ពលរដ្ឋកម្ពុជាយល់ដឹងពីសិទ្ធិ(ចេះស្គាល់សិទ្ធិ ចេះប្រើសិទ្ធិ ចេះគោរពសិទ្ធិ) រស់នៅដោយប្រសើរនិងថ្លៃថ្នូរ។

## គោលដៅ:

កាត់បន្ថយភាពក្រីក្រ និងអំពើអមនុស្សធម៌នៅក្នុងសង្គមកម្ពុជា។

## ទិសដៅ:

លើកកំពស់ជីវភាពជនងាយរងគ្រោះ(ទុរគតជន អ្នកផ្ទុក ជនពិការ កុមារកំព្រា ពលកម្មកុមារជនជាតិដើមភាគតិច..និងអ្នកបាត់បង់ឱកាសដោយបង្កើនចំណេះដឹងដល់សហគមន៍។

## បេសកកម្ម:

ធ្វើការជាមួយជនងាយរងគ្រោះ(ទុរគតជន អ្នកផ្ទុក ជនពិការ កុមារកំព្រា ពលកម្មកុមារជនជាតិដើមភាគតិច...) និងអ្នកបាត់បង់ឱកាស ដើម្បីឲ្យពួកគេទទួលបានចំណេះដឹង ហើយពួកគេមានសមត្ថភាព និងមានលទ្ធភាពទាមទារសិទ្ធិរស់នៅដោយប្រសើរនិងថ្លៃថ្នូរ។

## គុណតម្លៃ:

- រស់នៅជាមួយពលរដ្ឋ
- រៀនសូត្រពីពលរដ្ឋ
- អប់រំដល់ពលរដ្ឋ

## ពាក្យស្លោក:

១.បង្កើតការងារ មិនសុំការងារ
២. បង្រៀនស្ទូចត្រី មិនឲ្យត្រីស៊ី
៣.មិនជួលឲ្យស្នេហ៍
តែប្រៀនឲ្យស្និទ្ធ ។

**ទីតាំងគោលដៅ**

| ខេត្ត | ស្រុក | ឃុំ | ភូមិ |
|---|---|---|---|
| កំពង់ចាម | ព្រៃឈរ | មៀន (១០ភូមិ) | ឃ្លោយទី២ ឃ្លោយទី៣ ឃ្លោយទី៤ អូរសង្កែ ដំណាក់ពង្រ ទួលព្រិច កំពង់សំណាញ់ ដីក្រហម កោះ និងកំពង់សំរិទ្ធ |
| | | ត្រពាំងព្រះ(៨ភូមិ) | កកោះ ចចក គូ ត្រពាំងស្វាយ ទន្លេ ស អូរដូនញា ពូនប្រមាត់ កោះស្វាយ និងត្រពាំងល័ក្ខ |

**ក្រុមគោលដៅ:** គម្រោងផ្តោតលើគ្រួសារ១៣៦០នៅក្នុង១៨ភូមិគោលដៅ។ គ្រួសារទាំង១៣៦០ ដែលចាត់ទុកជាក្រុមគោលដៅផ្ទាល់នោះ គឺ១. គ្រួសារក្រីក្រ ដែលមានដីតិចជាង០.៥ហិកតា ខ្វះបច្ចេកទេសកសិកម្ម ខ្វះប្រព័ន្ធធារាសាស្ត្រនិងខ្វះធនធានធ្វើកសិកម្ម ២. ប្រជានេសាទខ្នាតតូច តាមលក្ខណៈបុរាណនៅក្នុង១០ភូមិគោលដៅក្នុងឃុំមៀន ដែលពឹងអាស្រ័យយ៉ាងខ្លាំងលើបឹង២គឺបឹងកេះនិងបឹងធំ។

**គោលបំណង:** បន្តពង្រឹងសន្តិសុខស្បៀងសម្រាប់កសិករខ្នាតតូច ៣៩០ គ្រួសារ និងប្រជានេសាទតូចតាច ២៥ គ្រួសារ ដែលភាគច្រើនជាគ្រួសារមានស្ត្រីនិងកុមារច្រើនក្នុងបន្ទុក តាមរយៈការអនុវត្តកសិកម្មនិរន្តរភាពដែលធន់នឹងការប្រែប្រួលអាកាសធាតុ វារីវប្បកម្ម សិទ្ធិគ្រប់គ្រងធនធានធម្មជាតិ និងលើកកម្ពស់ការចូលរួមរបស់កុមារគូសារចំនួន ៤៣៤ នាក់ តាមគំនិតផ្តួចផ្តើមរបស់ក្រុមក្លឹបកុមារ នៅភូមិគោលដៅទាំង១៨ក្នុងខេត្តកំពង់ចាម។

## ២. ផែនការសកម្មភាព និងលទ្ធផលសំរេចបានក្នុងឆ្នាំ២០១៦

ឆ្នាំ២០១៦ អង្គការសាមគ្គីបានពង្រឹងកម្មវិធីបង្កើនចំណូលបន្ថែមផ្គត់ផ្គង់ជីវភាពតាមរយៈការងារកសិកម្មនិរន្តរភាព ដោយអនុវត្តកម្មវិធីគំនិតផ្តួចផ្តើមនៃការផ្លាស់ប្តូរបទពិសោធន៍ក្នុងចំណោមកសិករ កម្មវិធីគាំពារកុមារ និងការអប់រំ និងការគ្រប់គ្រងធនធានធម្មជាតិ។ ការគ្រប់គ្រងធនធានធម្មជាតិនេះ ធ្វើឡើងតាមរយៈការគាំទ្រគណកម្មការសហគមន៍នេសាទសាមគ្គីឃុំមៀនធ្វើសកម្មភាពចុះល្បាតបង្រ្កាបបទល្មើសនេសាទ គាំទ្រការផ្សព្វផ្សាយពីច្បាប់ជលផល។ ឯគណកម្មការសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រតាកុតវិញគឺគាំទ្រដឹកនាំការប្រជុំប្រធានក្រុមស្រែប្រាំងជាប្រចាំដើម្បីរក្សា និងគ្រប់គ្រងទឹកសំរាប់ស្រោចស្រពស្រែប្រាំង។ កម្មវិធីគាំពារកុមារ និងការអប់រំគឺផ្តោតលើសកម្មភាពប្រមូលសារ និងការគាំទ្រសំភារៈសិក្សា សំភារៈក្លឹបកុមារ ដើម្បីបង្កើនចំណេះដឹង និងពង្រឹងគុណភាពសារកុមារ។ ជាមួយគ្នានេះសាមគ្គីក៏បានទទួលការគាំទ្រថវិកាពីអង្គការNEPដើម្បីរៀបចំវេទិកាសវនកម្មសង្គមនៅសាលាបឋមសិក្សាចំនួន៣ ស្តីពីការអភិវឌ្ឍបរិស្ថានសាលារៀន ហើយយើងក៏បានគាំទ្រធុងចំពោះដល់សាលាបឋមសិក្សាចំនួន៧ផងដែរក្នុងឃុំមៀន និងត្រពាំងព្រះ។ ខាងក្រោមនេះគឺជាការរៀបរាប់លំអិតទៅតាមលទ្ធផល និងសកម្មភាពដូចតទៅ៖

**លទ្ធផលរពឹងទុកទី១៖** *កសិករទាំងចាស់ទាំងថ្មីចំនួនចំនួន ១៣៣នាក់ (ស្ត្រី៨៧នាក់) ក្នុងភូមិចំនួន១០ ឃុំចំនួន២ អនុវត្តកសិកម្មនិរន្តរភាពដែលធន់នឹងបំរែបំរួលអាកាសធាតុ។ ជីវភាពរបស់កសិករ២៣៥នាក់(ស្ត្រី១២៥នាក់)មានភាពប្រសើរឡើងតាមរយៈការអនុវត្តការងារកសិកម្ម ដោយមានការគ្រប់គ្រង ទឹកទំនប់តាកុត និងទំនប់ថ្មដំរីយ៉ាងមានប្រសិទ្ធិភាព។ ជាមួយគ្នានេះ អាជ្ញាធរមូលដ្ឋាន បានចូលរួមសកម្មទាំងស្មារតី និងសំភារៈ ដើម្បីការត្រៀមបង្ការគ្រោះមហន្តរាយ ពិសេសគ្រោះទឹកជំនន់។*

**សកម្មភាពដើម្បីសម្រេចលទ្ធផលទី១៖**

**១.១. សិក្ខាសាលាឆ្លុះបញ្ចាំងពីលទ្ធផលអនុវត្តរបស់កសិករទាំងចាស់ទាំងថ្មី៣៥នាក់**

សិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំត្រីមាសពីលទ្ធផលនៃការអនុវត្តរបស់កសិករគំរូនិងកសិករពង្រីក ត្រូវបានរៀបចំចំនួន៤លើកនៅការិយាល័យសាមគ្គី។ លើកទី១មានអ្នកចូលរួមចំនួន២៧នាក់ ស្រីចំនួន២៣នាក់។ ត្រីមាសទី១កសិករបានដាំដុះបានតិចតួចសំរាប់ផ្គត់ផ្គង់គ្រួសារប៉ុណ្ណោះ។ ត្រីមាសទី២ មានកសិករចូលរួមចំនួន ២៦នាក់ ស្រី២២នាក់។ត្រីមាសនេះគឺកសិករពុំទទួលបានផលពីការដាំដុះនោះទេ ព្រោះរាំងស្ងួតពុំមានទឹកស្រោចស្រព។ ត្រីមាសទី៣ មានកសិករចូលរួម៣៦នាក់ ស្រី២២នាក់។ តាមរយៈរបាយការណ៍ និងការពិភាក្សាក្រុមឃើញថា កសិករបានចាប់ផ្ដើមដាំដុះឡើងវិញដោយសារមានភ្លៀងធ្លាក់។ លទ្ធផលនៃការដាំដុះទទួលបានសំរាប់ផ្គត់ផ្គង់គ្រួសារ និងបានលក់នៅទីផ្សារ។ ចំណែកត្រីមាសទី៤ មានកសិករចូលរួមចំនួន៣៦នាក់ ស្រី២៩នាក់។ ត្រីមាសនេះកសិករក៏ពុំសូវទទួលបានផលច្រើនទេ ដោយសារភ្លៀងធ្លាក់ច្រើនធ្វើអោយរលួយខូចដំណាំបន្លែ ហើយបន្លែក៏មានតំលៃថោក ដោយសារប្រជាជនអាចដាំដុះបានប្រើប្រាស់សំរាប់គ្រួសារនិមួយៗ។ ជារួមនៅឆ្នាំ២០១៦នេះឃើញថា កសិករបានតស៊ូដាំដុះយ៉ាងស្វិតស្វាញ តែមានបញ្ហាច្រើនដូចជាខ្វះទឹកស្រោច អាកាសធាតុក្ដៅពេក ខ្វះពូជដំណាំ ជម្ងឺសត្វមាន់ ទាជាដើម។ បញ្ហាទាំងនេះធ្វើអោយកសិករភាគច្រើនបោះបង់ចោលការដាំដុះ និងធ្វើចំណាកស្រុកដើម្បីរកចំណូលផ្គត់ផ្គងគ្រួសារ។

**១.២.បន្តតាមដាន និងកែលំអការអនុវត្តរបស់កសិករគំរូដែលមានស្រាប់**

កសិករគម្រូ និងពង្រីកចំនួន៤៩៦នាក់នៅយគោលដៅទាំងពីរ (មៀននិងត្រពាំងព្រះ) ត្រូវបានតាមដានចំនួន១១លើកក្នុងឆ្នាំ២០១៦។ កសិករគម្រូ និងបុគ្គលិកបានពិនិត្យជាក់ស្ដែងឃើញថា ជារួមកសិករបានដំណើរការដាំដុះបន្លែរួមមានត្រសក់ សណ្ដែកគួរ សាលាត់ ត្រកួន ននោង ម្រះ ស្ពៃធំ ស្ពៃក្រញាញ់ ស្ពៃចង្កឹះ សណ្ដែកបាយ ពោត ត្រប់ និងល្ពៅតាមបច្ចេកទេស។ នៅឆ្នាំ២០១៦នេះ មុខរបរនេះពុំសូវទទួលបានផលទេ ដោយសារតែ កសិករជួបនូវបញ្ហាប្រឈមជាច្រើន ដូចជាអាកាសធាតុក្ដៅ រាំងស្ងួត គ្មានទឹកស្រោចស្រព សត្វល្អិតបំផ្លាញ ជម្ងឺសត្វមាន់ ទា និងកសិករចំណាកស្រុកនៅអំឡុងត្រីមាសទី១ដល់ទី៣ ហើយនៅត្រីមាសទី៤វិញគឺភ្លៀងធ្លាក់ជាបន្តបន្ទាប់ក៏ធ្វើអោយរលួយខូចដំណាំ និងលិចលង់ស្រូវយ៉ាងធ្ងន់ធ្ងរផងដែរ។

**១.៣. បង្ហាត់បង្ហាញផ្ទាល់ដល់កសិករពង្រីក ដែលមានស្រាប់**

កសិករគំរូ និងកសិករពង្រីកចំនួន៩៦នាក់ស្រី៧៨នាក់នៅក្នុងភូមិចំនួន៥ក្នុងឃុំមៀន និងឃុំត្រពាំងព្រះបានទទួលចំណេះដឹង និងបទពិសោធន៍ពីរបៀបធ្វើជីកំប៉ុស្តិទឹក កំប៉ុស្តិ៍គោក ជីអ៊ីអឹម ថ្នាំបណ្ដេញសត្វល្អិតធម្មជាតិ និងរបៀបដាំបន្លែ(ត្រសក់ សាលាត់ ត្រកួន និងត្រប់)។ វគ្គនេះរៀបចំនៅតាមភូមិដើម្បីពង្រឹងបច្ចេកទេសដល់កសិករពង្រីក និងកសិករគំរូ។ វគ្គនេះសំរបសំរួលដោយតំណាងកសិករគំរូចំនួន៤នាក់។ កំឡុងពេលនៃវគ្គបង្ហាត់បង្ហាញ សង្កេតឃើញថា កសិករដែលបានចូលរួមទាំងអស់យល់ដឹងច្បាស់ពីបច្ចេកទេសធ្វើជី ធ្វើថ្នាំបណ្ដេញសត្វ និងបច្ចេកទេសដាំបន្លែ។ បន្ទាប់ពីវគ្គបង្ហាត់បង្ហាញនេះ តំណាងកសិករ និងបុគ្គលិកទទួលបន្ទុកបានតាមដាន និងដឹកនាំប្រជុំឆ្លុះបញ្ចាំង១លើក ឃើញថាកសិករបានអនុវត្តន៍ទៅតាមបច្ចេកទេសដែលទទួលបានពីការបង្ហាញ។

**លទ្ធផលរំពឹងទុកទី២៖** *ប្រជានេសាទចំនួន៤០០នាក់ (ស្ត្រីចំនួន១៦៥នាក់)បានស្គាល់ពីសិទ្ធិ ប្រើសិទ្ធិ ចូលរួមគ្រប់គ្រងដែននេសាទសហគមន៍ប្រកប ដោយនិរន្តរភាព ដើម្បីធ្វើអោយបរិមាណត្រីកើន និងបង្កើនចំណូលគ្រួសារ។ ប្រជានេសាទចំនួន១០នាក់ (ស្ត្រីចំនួន២នាក់) បាននឹងកំពុងសាកល្បងអនុវត្តវារីវប្បកម្មលើកតំបូង*

*ដើម្បីបង្កើនចំណូលបន្ថែមដល់គ្រួសារ ក៏ដូចជាគំរូដល់ប្រជានេសាទដទៃទៀត និង គណៈកម្មការមានសមត្ថភាពដឹកនាំ មានផែនការច្បាស់លាស់។*

## សកម្មភាពដើម្បីសម្រេចលទ្ធផលទី២៖

## ២.១. ប្រជុំឆ្លុះបញ្ចាំងជាមួយកសិករចិញ្ចឹមត្រី

ការប្រជុំនេះត្រូវបានរៀបចំឡើងចំនួន៣លើក ដើម្បីចែករំលែកពីលទ្ធផល និងបញ្ហាប្រឈមនៃការចិញ្ចឹមត្រី ដែលមានកសិករចិញ្ចឹមត្រីចំនួន៩នាក់ ស្រី៣នាក់មកពីភូមិទួលព្រិច កំពង់សំណាញ់ និងកេះបានចូលរួម។ ជាលទ្ធផលសង្កេតឃើញថា កសិករចំនួន៣នាក់កំពុងបន្តចិញ្ចឹមត្រី(២នាក់កំពុងចិញ្ចឹមត្រីប្រាចំនួន២០០០ទៅ៥០០០ក្បាល ឯ១នាក់ទៀតកំពុងចិញ្ចឹមត្រីអណ្តែង)។ ចំណែកកសិករ៦នាក់ផ្សេងទៀតមិនបានចិញ្ចឹមទេ ដោយសារខ្វះសំភារៈ(បែរ និងថវិកាចំណាយ)។ តាយរយៈការតាមដាន ឃើញថា ការចិញ្ចឹមត្រីមិនមានដំណើរការប្រសើរទេ។ ផ្ទុយទៅវិញកសិករបានបោះបង់ការចិញ្ចឹមត្រី ហើយបែរទៅរករបរផ្សេងៗ ដោយគាត់យល់ថាពិបាកគ្រប់គ្រង និងចំណាយច្រើន។

## ២.២. តាមដាន និងគាំទ្រគណៈកម្មការចុះល្បាតបទល្មើសនេសាទ

គណៈកម្មការសហគមន៍នេសាទសាមគ្គីឃុំមៀនបានសហការជាមួយមន្ត្រីជលផល អាជ្ញាធរឃុំ នគរបាលឃុំ មេភូមិពាក់ព័ន្ធ និងប្រជាពលរដ្ឋបានចុះល្បាត និងបង្ក្រាបបទល្មើសនេសាទចំនួន១៨លើកក្នុងឆ្នាំ២០១៦នេះ។ ជាមួយគ្នានេះ សាមគ្គីបានគាំទ្រការជួសជុលម៉ាស៊ីនចំនួន២គ្រឿងសំរាប់សហគមន៍នេសាទសាមគ្គីឃុំមៀន និងគាំទ្រការជួសជុលទូកចំនួន២គ្រឿងដល់ក្រុមគណៈកម្មការតាកុត។ ជាលទ្ធផលកំឡាំងល្បាតបានប្រមូលបានលូស្បៃម៉ុងចំនួន៣២៣មាត់ ព្រួលស្បៃម៉ុង៧,៣៧៥ម៉ែត្រ រនាំងព្រួល៣ខ្សែ ចាក់លែងកូនត្រីចំរុះចំនួន១៥២គីឡូក្រាម បង្គោលវ៉ាវ១៨០ដើម ទូកចំនួន៤ ក្បាលឆក់ និងអាគុយ១គ្រឿង និងវ៉ាវ ៤មាត់។ កំលាំងចុះល្បាត និងបង្ក្រាបបទល្មើស៖ ប្រជាពលរដ្ឋ មេភូមិ ប៉ូលីស ក្រុមប្រឹក្សាឃុំ គណៈកម្មការសហគមន៍ និងសមត្ថកិច្ចជលផលសរុបចំនួនចំនួន ៣១៣នាក់។ ឧបករណ៍នេសាទខុសច្បាប់ទាំងនោះត្រូវបានកាប់កំទេច និងដុតចោលទាំងអស់។ តាមរយៈសកម្មភាពនេះសង្កេតឃើញថា បទល្មើសនេសាទមានបានថយចុះស្ទើរតែ១០០%ក្នុងរដូវបិទនេសាទ។ ឆ្នាំ២០១៦នេះគឺមានការគាំទ្រពីប្រជាពលរដ្ឋ(ចូលរួមទូកកំលាំងកាយ ថវិកា ទឹកសុទ្ធ សាំង អាហារសំរន់ តែមិនស្ថិតស្ថេរនោះទេ)។ គណៈកម្មការសហគមន៍នេសាទសាមគ្គីឃុំមៀនទទួលបានទូកស្ទាច់១គ្រឿងពីរដ្ឋបាលជលផលកំពង់ចាម។

## ២.៣.ប្រជុំគណៈកម្មការសហគមន៍នេសាទប្រចាំឆមាស

ដឹកនាំប្រជុំគណៈកម្មការសហគមន៍នេសាទសាមគ្គីឃុំមៀនបានចំនួន៣លើក ដែលមានអ្នកចូលរួមសរុបចំនួន ៥១នាក់ ស្រី៥នាក់ (៣លើក)។ ជាលទ្ធផល គណៈកម្មការបានរាយការណ៍ថា អង្គការសាមគ្គីបានគាំទ្រការជួសជុលម៉ាស៊ីនចំនួន២គ្រឿង និងគាំទ្រសកម្មភាពល្បាត។ រដ្ឋបាលជលផលកំពង់ចាមបានគាំទ្រទូកចំនួន១គ្រឿងសំរាប់ដឹកជញ្ជូនសំភារៈទៅកន្លែងអភិរក្ស(បឹងព្រលឹត)និងទូកស្ទាច់១គ្រឿងសំរាប់ល្បាត។ បញ្ហាជួបប្រទះគឺបទល្មើសនេសាទនៅតែកើតមានច្រើន។ គណៈកម្មការនិងសមាជិកបានដឹកនាំចុះល្បាត ហើយបានកសាងរបាយការណ៍ រូបថតដាក់ជូនឃុំ ស្រុកដើម្បីសុំការអន្តរាគមន៍។ សំណើថវិកាទៅសមាគមន៍យុវជនខ្មែរ(KYA) និងសំណើមួយផ្សេងទៀតស្នើទៅខ័ណ្ឌរដ្ឋបាលជលផលខេត្តកំពង់ចាម ដើម្បីសុំការគាំទ្រនិងរកម្ចាស់ជំនួយសំរាប់ផែនការគ្រប់គ្រងរបស់សហគមន៍នេសាទ

សាមគ្គីឃុំមៀនត្រូវបានពិភាក្សា តែពុំមានការឆ្លើយតប។ ទោះយ៉ាងណា គណៈកម្មការ ក្រុមប្រឹក្សាឃុំ មេភូមិ និងតំណាងប្រជាពលរដ្ឋចូលរួមល្បាត និងសហការបង្រ្កាបបទល្មើសនេសាទក្នុងដែនសហគមន៍យ៉ាងសកម្ម។

**លទ្ធផលរំពឹងទុកទី៣.** *គណៈកម្មការទំនប់ប្រឡាយ ស្រះ អណ្តូង និងប្រធានក្រុមប្រើប្រាស់ទឹកចំនួន២៥នាក់ (ស្ត្រីចំនួន១៣នាក់) បានទទួលចំណេះដឹង បទពិសោធន៍ មានបទបញ្ជាផ្ទៃក្នុង ហើយអាចដឹកនាំគ្រប់គ្រងប្រើប្រាស់ធារាសាស្ត្រ(ទំនប់ប្រឡាយ ស្រះ អណ្តូង)ជាពិសេសតំបន់ធារាសាស្ត្រតាកុត និងសហគមន៍ប្រកបដោយនិរន្តរភាព។*

**សកម្មភាពដើម្បីសម្រេចលទ្ធផលទី៣៖**

### ៣.១. ប្រជុំឆ្លុះបញ្ជាំងពីដំណើរការប្រើប្រាស់ទឹករវាងគណៈកម្មការតាកុត និងប្រធានក្រុមស្រែប្រាំង

ដឹកនាំប្រជុំគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹកតាកុត និងប្រធានក្រុមស្រែប្រាំងចំនួន៥លើក។ ការប្រជុំនេះធ្វើឡើងដើម្បីចែករំលែកឆ្លុះបញ្ជាំងពីដំណើរការ និងលទ្ធផលនៃការប្រើប្រាស់ទឹក។ គណៈកម្មការមានការគ្រប់គ្រងចែកចាយទឹកស្រោចស្រពបានល្អ បើទោះជាឆ្នាំ២០១៦នេះ មានភាពរាំងស្ងួតហួតហែងយ៉ាងណាក៏ដោយ តែគណៈកម្មការបានខិតខំគ្រប់គ្រងនិងថែទាំទឹកសំរាប់ប្រើប្រាស់បានគ្រប់គ្រាន់ទៅតាមតំរូវការរបស់ប្រជាពលរដ្ឋ។ ឯអ្នកធ្វើស្រែខាងក្នុងអាង និងខាងលើអាង ខ្វះខាតទឹកតិចតួច ដោយសារតែអាកាសធាតុហួតហែងខ្លាំង ទឹករីងលឿន។ ចំណុចវិជ្ជមានមួយទៀតគឺក្រុមប្រឹក្សាឃុំមៀនបានកសាងផ្លូវពីភូមិកេះ ដីក្រហមទៅកាន់ទំនប់តាកុតទៅតាមការសន្យា ដែលបង្កភាពងាយស្រួលដល់ការធ្វើដំណើរ និងការទៅកំសាន្តនៅតំបន់តាកុត។ ប៉ុន្តែក៏មានបញ្ហាមួយចំនួនដែលកសិករជួបប្រទះគឺការនាំទឹកទៅស្រែខាងក្រោមមិនចំគោលដៅ ប្រឡាយដាច់ និងរីងរាក់ ដោយសារទឹក និងដីហូរចូល។ ទឹកហូរបាចសាចនាំឲ្យប៉ះពាល់ដល់ស្រូវជិតខាងដែលទុំហើយ និងបញ្ហាសត្វល្អិត និងកណ្តុរបំផ្លាញយ៉ាងធ្ងន់ធ្ងរ។ ម្យ៉ាងទៀត ការបើកបិទទំនប់រលំពោធិក៏បានបង្ករការប៉ះពាល់ដល់ការធ្វើស្រែទាំងលើនិងខាងក្រោមផងដែរ(ខាងលើទឹកច្រើនធ្វើស្រែមិនកើត ឯខាងក្រោមត្រូវលិចលង់រលួយស្រូវដែលទើបតែព្រោះ បើសិនទ្វារទឹកត្រូវបានបើក)។ អង្គប្រជុំបានដាក់សំណើសុំក្បាលឆក់សំរាប់ឆក់កណ្តុរ និងសុំគាំទ្របច្ចេកទេសកំចាត់សត្វល្អិតទៅការិយាល័យកសិកម្ម។ មន្ទីរកសិកម្ម និងការិយាល័យកសិកម្មបានចុះអន្តរាគមន៍ភ្លាមៗនៅចំណុចស្រែប្រាំងដែលមានការបំផ្លាញ(ខាងក្រោមតាកុត និងបរិវេណបឹងកេះ)តាមសំណើរ តែមិនផ្តល់សំភារៈឆក់កណ្តុរទេ។ ចុងត្រីមាសទី៣ និងទី៤ ភ្លៀងធ្លាក់ជាប់ៗគ្នាបង្កអោយមានការលិចលង់ស្រូវវស្សាខាងលើអាងតាកុតជាច្រើនហិកតា និងខូចខាតទំនប់ប្រឡាយជាច្រើនកន្លែង។

### ៣.២. ប្រជុំគណៈកម្មការស្រះតាពេញ ទំនប់កន្លែងចក និងទំនប់ថ្មដំរីប្រចាំឆមាស

ដឹកនាំប្រជុំគណៈកម្មការស្រះតាពេញ ទំនប់កន្លែងចក និងទំនប់ថ្មដំរីចំនួន២លើក។ ការប្រជុំនេះរៀបចំឡើងដើម្បីចែករំលែកឆ្លុះបញ្ជាំងពីការប្រើប្រាស់ទឹក និងស្ថានភាពបច្ចុប្បន្នរបស់ទំនប់និមួយៗ។ ស្រះតាពេញមានទឹកច្រើនអាចប្រើប្រាស់សំរាប់សត្វផឹក ស្រោចស្រពស្រូវវស្សា និងដំណាំ។ ទំនប់កន្លែងចក៤ឆ្នាំដំបូងដំណើរការបានរលូនសំរាប់ស្រែប្រាំង និងទទួលបានផលត្រី ប៉ុន្តែ៣ឆ្នាំចុងក្រោយនេះមានបញ្ហាខ្លះៗ ដោយសារការបើកបិទទ្វារទឹកទំនប់រលំពោធិមិនទៀងទាត់។ បញ្ហានេះត្រូវបានដោះស្រាយរួចរាល់ ហើយឆ្នាំខាងមុខនឹងស្នើបញ្ចូលទៅក្នុងផែនការវិនិយោគឃុំ។

ទំនប់ថ្មដំរី មានទឹកស្រោចស្រពគ្រប់គ្រាន់។ ប៉ុន្តែប្រឡាយនៅរាក់(គើយថ្មដា)មិនអាចនាំទឹកបានទៅដល់ស្រែឆ្ងាយៗ។ គណៈកម្មការបានលើកសំណើស្តារប្រឡាយនេះចូលក្នុងផែនការវិនិយោគឃុំរួចរាល់។

### ៣.៣. ប្រជុំក្រុមអណ្តូងបន្លែ និងស្រែប្រាំង(អូរសង្កែ កេះ និងដីក្រហម

សំរបសំរួលការប្រជុំតំណាង និងសមាជិកក្រុមអណ្តូងចំនួន៣លើក។ ក្រុមអណ្តូងភូមិអូរសង្កែភូមិអូរសង្កែមានចំនួន២កន្លែង(ក្នុងភូមិ)សំរាប់ប្រើប្រាស់ និងស្រោចបន្លែ។ ភូមិដីក្រហមមានអណ្តូង២កន្លែង និងភូមិកេះមានចំនួន៣កន្លែងសំរាប់ប្រើប្រាស់សង្គ្រោះស្រូវប្រាំង និងស្រូវបណ្តោញទឹក។ អណ្តូងទាំងនេះត្រូវបានប្រើប្រាស់ល្អ មានទឹកប្រើប្រាស់គ្រប់គ្រាន់។ ផែនការបន្តត្រូវជីកអណ្តូងបន្ថែម ដោយក្រុមនិមួយៗត្រូវប្រមូលថវិកាពីសមាជិកដើម្បីជីក។ ដើម្បីនិរន្តរភាពក្រុមសមាជិកក្រុមបានប្រជុំកំណត់យកបដិភាគជាស្រូវកន្លះគីឡូក្រាម(០.៥គីឡូក្រាម) ឬជាលុយចំនួន៥០០រៀលក្នុងផ្ទៃដី១អាពីសមាជិកម្នាក់ក្នុង១រដូវចាប់ពីឆ្នាំ២០១៧តទៅ។

**លទ្ធផលរំពឹងទុកទី៤:** *ក្រុមនិមួយៗ(គោ ទុនបង្វិល ម៉ាស៊ីនបូមទឹក ធនាគារស្រូវ និងក្រុមស្តារឆ្នោត)ក្នុង១៩ភូមិ ២ឃុំ បានធ្វើបច្ចុប្បន្នភាព ហើយលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងបានរៀបចំកែសម្រួល ហើយមានពត៌មានសមាជិក និងអនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងដោយរលូន។*

**សកម្មភាពដើម្បីសម្រេចលទ្ធផលទី៤៖**

### ៤.១. ប្រជុំតំណាងក្រុម ជនបង្គោលត្រួតពិនិត្យឡើងវិញពីដំណើរការក្រុមតាមភូមិ

ជនបង្គោល មេភូមិ និងតំណាងក្រុមកសិករចំនួន៣២នាក់ ស្រី២២នាក់មកពី២ឃុំ(មៀន និងត្រពាំងព្រះ)បានចូលរួមប្រជុំឆ្លុះបញ្ចាំងពីដំណើរការរបស់ក្រុមតាមភូមិចំនួន១លើកនៅការិយាល័យសាមគ្គី។ ជាលទ្ធផល ផែនការប្រជុំភូមិ និងអ្នកទទួលខុសត្រូវតាមភូមិត្រូវបានរៀបចំ។ ជនបង្គោល និងតំណាងក្រុមទៅតាមផែនការប្រជុំតាមភូមិនិមួយៗ ស្រង់ស្ថិតិសមាជិក ស្រង់បញ្ហា និងប្រមូលថវិកាក្រុម ហើយរក្សានៅធនាគារ។ បន្ទាប់មក ប្រជុំបូកសរុបរៀបចំផែនការប្រើប្រាស់ថវិកាតាមភូមិនិមួយៗទៅតាមសក្តានុពល និងបញ្ហាអទិភាព។

### ៤.២. ប្រជុំត្រួតពិនិត្យ និងប្រមូលទុនតាមភូមិ

ការប្រជុំនេះត្រូវបានរៀបចំឡើង២លើក ដោយមានការចូលរួមពីជនបង្គោល មេភូមិ និងតំណាងក្រុមកសិករ ដើម្បីរំលឹក និងតាមដានដំណើរការប្រជុំប្រមូលថវិកាត្រឡប់។ ប្រជុំត្រួតពិនិត្យនេះធ្វើឡើងនៅតាមភូមិ។ ជនបង្គោល និងប្រធានក្រុមបានកំណត់ពេលវេលា និងតាមដានសមាជិកដែលត្រូវប្រមូលថវិកា។ ប៉ុន្តែការប្រមូលថវិកាតាមភូមិនេះមិនទាន់មានសមាជិកណាម្នាក់បានប្រគល់ថវិកានោះទេ ដោយសារសមាជិក និងប្រធានក្រុមទាំងនោះបានធ្វើចំណាកស្រុក។ ម្យ៉ាងទៀត ក្រៅពីចំណាកស្រុក អ្នកដែលនៅសល់មិនបានចូលរួមប្រជុំតាមការកំណត់ ដោយឆ្លើយថាជាប់រវល់។ ជាងនេះទៅទៀត សាមគ្គីក៏បានសំរបសំរួលតំណាងក្រុម មេភូមិ ជនបង្គោលសរុបចំនួន១៦នាក់ ស្រីចំនួន១៣នាក់បានចូលួមប្រជុំដើម្បីធ្វើផែនការទុនបង្វិល និងផ្ទៀងផ្ទាត់ឡើងវិញកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦នៅអង្គការសាមគ្គី។ ជាលទ្ធផលឯកសារទុនបង្វិលត្រូវបានពិភាក្សា និងផ្ទៀងផ្ទាត់ទាំងចំនួនសមាជិក ទាំងចំនួនទឹកប្រាក់ដែលបានខ្ចីពីក្រុម។

**លទ្ធផលរំពឹងទុកទី៥៖** *ពង្រឹងតំណាងក្លឹបកុមារ១២ភូមិដែលមានសមាជិកក្លិបចំនួន ៤៣៤នាក់ ដើម្បីចូលរួមក្នុងកម្មវិធីអភិវឌ្ឍភូមិ ឃុំ និងបង្កើនគុណភាពសារ។ ជាងនេះទៅទៀត តំណាងក្លឹបកុមារបានចូលរួមប្រជុំ និងភ្ជាប់ទំនាក់ទំនងជាមួយបណ្តាញ ឬអង្គការដែលធ្វើការលើផ្នែកកុមារ។*

**សកម្មភាពដើម្បីសម្រេចលទ្ធផលទី៥៖**

**៥.១. បណ្តុះបណ្តាលតំណាងក្លឹបកុមារពីគោលគំនិតនៃភាពជាដឹកនាំ ការងារក្រុម ការអភិវឌ្ឍសហគមន៍**

តំណាងក្លឹបកុមារ និងសមាជិកចំនួន៣៧នាក់ ស្រី៣១មកពីភូមិចំនួន១២ នៃឃុំមៀន និងឃុំត្រពាំងព្រះបានទទួលចំណេះដឹងពីគោលគំនិតនៃភាពជាអ្នកដឹកនាំ ការចងក្រងនិងអភិវឌ្ឍន៍សហគមន៍រយៈពេល២ថ្ងៃនៅអង្គការសាមគ្គី។ កំឡុងពេលនៃវគ្គបណ្តុះបណ្តាលឃើញថា តំណាងក្លឹបកុមារ និងសមាជិកចំនួន៧០% នៃអ្នកចូលរួមបានយល់ដឹងពីខ្លឹមសារ អាចពន្យល់បកស្រាយ ក្លាហានហ៊ានបញ្ចេញមតិ និងសួរសំនួរមកកាន់អ្នកសំរបសំរួល។ កុមារ៣០%ទៀតមានការយល់ដឹងពីខ្លឹមសារនៅមានកំរិតទាប។ ចុងបញ្ចប់នៃវគ្គពួកគេបានតាំងចិត្តអនុវត្តចែករំលែកចំណេះដឹងនេះដល់សមាជិករបស់គេអោយអស់ពីសមត្ថភាព។ ពួកគេក៏បានសំណូមពរអោយមានវគ្គនេះលើកក្រោយទៀត។

**៥.២. ប្រជុំតំណាងក្លឹបកុមារតាមដានពីដំណើរការ និងបញ្ហាកុមារ**

ឆ្នាំ២០១៦នេះ សាមគ្គីបានរៀបចំការប្រជុំតំណាងក្លឹបកុមារ និងជនបង្គោលដើម្បីឆ្លុះបញ្ចាំងពីដំណើរការ និងបញ្ហាកុមារចំនួន២លើក។ ជាលទ្ធផលឃើញថា តាមក្លឹបនិមួយៗមានសកម្មភាពដំណើរការធម្មតាគឺពួកគេនាំគ្នាមកអាន និងរៀនលេខអក្សរនៅថ្ងៃព្រហស្បត្តិ និងអាទិត្យពេលសំរាកពីសាលារៀន។ នៅចុងឆ្នាំវិញឃើញថា ស្ថានភាពក្លឹបកុមារមួយចំនួនមិនសូវមានសកម្មភាព ដោយសារសៀវភៅ ដែលបានគាំទ្រកន្លងមកចាស់(រឿងដដែលៗ ក្មេងធ្លាប់អានរួច) ហើយកុមារមួយចំនួនចំណាកស្រុកទៅតាមឪពុកម្តាយ។ ដោយឡែកបញ្ហាអប់រំវិញ ចំណេះដឹងនិងការយល់ដឹងរបស់ឪពុកម្តាយមានកំរិត ខ្វះការលើកទឹកចិត្ត និងការតាមដានពីការសិក្សារបស់កូន ជីវភាពក្រីក្រ កុមារមួយចំនួនបានចំណាកស្រុកដើម្បីជួយរកចំណូលឪពុកម្តាយ។ កុមារសំណូមពរអោយមានសៀវភៅថ្មីៗថែមទៀត។

**៥.៣. កម្មវិធីថ្ងៃប្រឌិតរូបភាព និងប្រលងគំនូរមុនប្រមូលសារកុមារ**

ឆ្នាំ២០១៦នេះបុគ្គលិកកម្មវិធីគាំពារកុមារ និងបុគ្គលិកស្ម័គ្រចិត្តបានសំរបសំរួលកម្មវិធីថ្ងៃប្រឌិតរូបភាព និងប្រលងគំនូរ១លើក។ កម្មវិធីនេះមានតំណាងក្លឹបកុមារ និងសមាជិក ជនបង្គោលសរុបចំនួន៦១៧នាក់ ស្រី ៤១៤នាក់នៅភូមិចំនួន១២បានចូលរួម។ កំឡុងពេលថ្ងៃប្រឌិតរូបភាព និងប្រលងគំនូរនេះ កុមារបានលេងកំសាន្តនិងបានញាំអាហាររួមគ្នាយ៉ាងសប្បាយរីករាយ។ ជាមួយគ្នានេះ កុមារក៏បានចូលរួមឆ្លើយសំនួរពីចំណេះដឹងទូទៅ អនាម័យខ្លួនប្រាណ និងទទួលបានរង្វាន់លើកទឹកចិត្ត។ សៀវភៅ ប៊ិច ខ្មៅដៃ បន្ទាត់សរុបចំនួន ៦១៧ឈុត ត្រូវបានចែកជូនដល់កុមារ ដែលបានចូលរួមទាំងអស់។ ក្រោយពីកម្មវិធីនេះឃើញថា កុមារមានសមត្ថភាព និងគូរសារបានល្អ និងមានគុណភាពប្រសើរជាមុន។

**៥.៤. ប្រជុំជនបង្គោលធ្វើផែនការប្រមូលសារកុមារ**

នៅឆ្នាំ២០១៦នេះ សាមគ្គីបានដឹកនាំប្រជុំធ្វើផែនការប្រមូលសារចំនួន២លើក ដែលមានជនបង្គោលអនុភូមិ និងតំណាងក្លឹបកុមារសរុបចំនួន៦៩នាក់ ស្រី៥៩នាក់ (២លើក) មកពីភូមិចំនួន១២ បានចូលរួម។ កិច្ច

ប្រជុំនេះ គឺផ្តល់ឱកាសឲ្យអ្នកចូលរួមបានចែករំលែកពត៌មានកុមារ និងបញ្ហានានាក្នុងភូមិ ជាពិសេសពត៌មានកុមារគួសារត្រូវបានធ្វើបច្ចុប្បន្នភាព។ រៀបចំផែនការ និងការទទួលខុសត្រូវយ៉ាងជាក់លាក់ដើម្បីងាយស្រួលក្នុងការប្រមូលសារកុមារ។ ក្រុមការងារបានចាប់អនុវត្តន៍សកម្មភាពនេះទៅតាមផែនការដែលបានគ្រោងទុក ឃើញថាមានប្រសិទ្ធភាព ទទួលបានសារ ដែលមានគុណភាព និងទាន់ពេលទៅតាមការគ្រោងទុក។

## ៥.៥. កម្មវិធីប្រមូលសារកុមារ១ឆ្នាំ២ដងនិងបញ្ច្រាបកម្មវិធីកុមារ

ការប្រមូលសារកុមារត្រូវបានធ្វើឡើងចំនួន២លើក។ លើកទី១កុមារដែលមានឈ្មោះត្រូវប្រមូលចំនួន២៦៥ ស្រី ១៤២នាក់។ ជាក់ស្តែងយើងទទួលបានចំនួន២៥០សារ(២៥០នាក់)។ ចំណែក១៥នាក់មិនត្រូវបានប្រមូលទេ ដោយសារគេចំណាកស្រុក។ លើកទី២មានកុមារចំនួន២២២នាក់ ស្រី១២០នាក់ត្រូវប្រមូល។ តែយើងទទួលបានចំនួន ២២២សារ (២២២នាក់)តាមបញ្ជីឈ្មោះ។ កុមារ២៨នាក់មិនត្រូវបានប្រមូលសារទេនៅលើកទី២ ព្រោះថាកុមារមួយចំនួនមានអាយុច្រើន ហើយមួយចំនួនទៀតត្រូវបានម្ចាស់ឧបត្ថម្ភឈប់គាំទ្រ។ បើប្រៀបធៀបទៅនឹងចំនួនកុមារសំរាប់ឆ្នាំ ២០១៦ ដែលមានកុមារចំនួន២៦៥នាក់ ហើយចុងឆ្នាំយើងនៅសល់កុមារចំនួន ២២២នាក់ ស្រី១២០នាក់ប៉ុណ្ណោះ។

## ៥.៦. ថតរូបបច្ចុប្បន្នភាព និងករណីសិក្សា

ឆ្នាំ២០១៦នេះ មន្ត្រីគាំពារកុមារ និងអ្នកស្ម័គ្រចិត្តបានថតរូបបច្ចុប្បន្នភាព ដោយផ្តោតលើការរីកចំរើនរបស់កុមារគួសារបានចំនួន៣៨៦នាក់ ស្រី២០៣នាក់។ រូបថតកុមារទាំងនេះ ត្រូវបានចែកជូនដល់កុមារគ្រប់គ្នា និងបានផ្ញើជូនទៅអង្គការអាក់សិនអេត។

## ៥.៧. តំណាងក្លឹបចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំលើបញ្ហាកុមារ និងការអប់រំ

តំណាងក្លឹបកុមារ និងបុគ្គលិកបានចូលរួមប្រជុំ ចំនួន១១លើកជាមួយក្រុមប្រឹក្សាឃុំ(ឃុំមៀន)។ ការចូលរួមប្រជុំនេះមានបំណងអោយតំណាងកុមារមានយល់ដឹងពីកិច្ចអភិវឌ្ឍន៍ភូមិឃុំ និងលើកឡើងនូវបញ្ហាសំណូមពរនានាក្នុងភូមិឬបញ្ហាទាក់ទងទៅនឹងកុមារ ការអប់រំ និងសុំកិច្ចអន្តរាគមន៍ពីសំណាក់ក្រុមប្រឹក្សាឃុំ និងអាជ្ញាធរមានសមត្ថកិច្ច។ ឆ្នាំ ២០១៦នេះ កិច្ចប្រជុំក្រុមប្រឹក្សាត្រូវបានរៀបចំនៅតាមភូមិ ដោយផ្តល់ឱកាសឲ្យអ្នកចូលរួមបានលើកឡើងនូវព័ត៌មាន និងបញ្ហាសម្រាម ការចំណាកស្រុក គ្រឿងញៀន ល្បែងស៊ីសង ដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ និងសមត្ថកិច្ចអន្តរាគមន៍។ ជាមួយគ្នានេះឃុំក៏បានជូនដំណឹងពីការធ្វើអត្តសញ្ញាណប័ណ្ណ ផ្សព្វផ្សាយការបន្តក់ថ្នាំការពារជម្ងឺ៥មុខ ដោះស្រាយទំនាស់អំពើហិង្សា និងការជួយសង្គ្រោះដល់អ្នករងគ្រោះដោយសារខ្យល់កន្ត្រាក់។ បញ្ហាខាងលើនេះត្រូវបានក្រុមប្រឹក្សាឃុំធ្វើអន្តរាគមន៍តាមលទ្ធភាព។

## ៥.៨. កម្មវិធីជប់លៀងលាកុមារគួសារ

កុមារគួសារ ជនបង្គោល មាតាបិតា គណៈកម្មការសហគមន៍នេសាទសាមគ្គីឃុំមៀន គណៈកម្មការតាកុត មេភូមិ ក្រុមប្រឹក្សាឃុំ ការិយាល័យអប់រំស្រុក និងអភិបាលរងស្រុកព្រៃឈរ សរុបចំនួន៣៥០នាក់ ស្រី១៨៦នាក់បានចូលរួមក្នុងកម្មវិធីជប់លៀងបិទគម្រោងកម្មវិធីគាំពារកុមារ និងភាពជាដៃគូរវាងអង្គការសាមគ្គី និងអង្គការអាក់សិនអេតកម្ពុជា។ កម្មវិធីនេះត្រូវបានរៀបចំនាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៦នៅស្នាក់ការអង្គការសាមគ្គីកំពង់ចាមក្នុងបំណងបូកសរុបរបាយការណ៍ និងប្រគល់សមិទ្ធផលនានារបស់អង្គការសាមគ្គីជូនសហគមន៍ និងអាជ្ញាធរ។ ជាងនេះទៅទៀត វាជាការជួបជុំលើកចុងក្រោយជាមួយកុមារក្នុងសហគមន៍ បង្កើតបរិយាកាសរីករាយសំរាប់កុមារ សហគមន៍ និងជាការជូនដំណឹងទៅដល់អ្នកចូលរួម ជាពិសេសកម្មវិធីគាំពារកុមារ និងអាជ្ញាធរចំពោះការដកខ្លួនចេញរបស់អង្គការអាក់សិនអេត និងថ្លែង

អំណរគុណចំពោះការចូលរួមចំណែកដ៏សំខាន់របស់កុមារគូរសារ គ្រួសារពួកគេក្នុងការស្វែងរកមូលនិធិមកអភិវឌ្ឍន៍សហគមន៍។ កម្មវិធីនេះប្រព្រឹត្តិទៅដោយភាពរីករាយជាមួយការលេងល្បែងប្រជាប្រិយ រាំកំសាន្តរហូតដល់ម៉ោង៣រសៀល បើទោះជាមានភ្លៀងរលឹមយ៉ាងណាក៏ដោយ។

**៥.៩. ថតវីដេអូស្តីពីការរីកចំរើនរបស់កុមារគាំពារ និងជំរាបលាកុមារចុងក្រោយ(Goodbye Video)**

**១១១៧-A1.របាយការណ៍CNL និង PRO** ៖

ឆ្នាំ២០១៦នេះ មន្ត្រីគាំពារកុមារបានចង់ក្រងរបាយការណ៍CNL និងបានផ្ញើជូនមន្ត្រីគាំពាំរកុមារអង្គការអាក់សិនអេតរួចរាល់។ លិខិតឆ្លើយឆ្លងក៏បានចែកជូនទៅដល់កុមារដោយបានសរសេរឆ្លើយតប និងបានថតរូបផ្ញើទៅមន្ត្រីគាំពារកុមារអង្គការអាក់សិនអេតរួចរាល់។ របាយការណ៍បញ្ចប់គម្រោងលើកម្មវិធីកុមារ ការអប់រំ និងសន្តិសុខស្បៀង ដោយរួមបញ្ចូលករណីសិក្សាគ្រប់ផ្នែកត្រូវបានរៀបចំ និងបានផ្ញើជូនអង្គការអាក់សិនអេតរួចរាល់។

**១១១៧-A2.សិក្ខាសាលាកម្មវិធីគាំពារកុមាររបស់បុគ្គលិក១ឆ្នាំ២ដង**: (សកម្មភាពនេះមិនត្រូវបានអនុវត្តទេ ដោយសារជាឆ្នាំបញ្ចប់គម្រោង ហើយអង្គការអាក់សិនអេតក៏ពុំបានអញ្ជើញអោយសាមគ្គីបានចូលរួមដែរ)។

**ការងារអប់រំ**

ឆ្នាំ២០១៦នេះ អង្គការសាមគ្គីកំពង់ចាមទទួលបានការគាំទ្រថវិកាពីអង្គការភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល(NEP) បានរៀបចំវេទិកាពិភាក្សាស្តីពីការអភិវឌ្ឍន៍បរិស្ថានសាលារៀនបឋមសិក្សាស្របតាមគោលការណ៍សាលាកុមារមេត្រីនៅសាលាបឋមសិក្សាចំនួន៣ក្នុងឃុំមៀននិងឃុំត្រពាំងព្រះ។ កិច្ចពិភាក្សានេះបានផ្តល់ឱកាសឲ្យមានការជួបជុំគ្នាចូលរួមផ្តល់មតិ និងគំនិតថ្មីៗពីអ្នកពាក់ព័ន្ធរួមមានមាតាបិតា គណៈកម្មការទ្រទ្រង់សាលា លោកគ្រូ អ្នកគ្រូ នាយកសាលា ការិយាល័យអប់រំ និងក្រុមប្រឹក្សាឃុំលើការកែលំអបរិស្ថានសាលារៀន និងគុណភាពអប់រំអោយប្រសើរ។ ជាងនេះទៀត អ្នកចូលរួមបានលើកឡើងនូវបញ្ហា និងសំណូមពរជូនអ្នកផ្តល់សេវា(ក្រុមប្រឹក្សាឃុំ នាយកសាលា និងមន្ត្រីការិយាល័យអប់រំស្រុក)ដើម្បីជួយរកដំណោះស្រាយ។ ឯខាងផ្តល់សេវាក៏បានទទួលយកសំណូមពរ ហើយដោះស្រាយជាបន្តបន្ទាប់ ដោយមានកំណត់ហេតុសំរាប់តាមដានយ៉ាងជាក់លាក់។ វេទិកាពិភាក្សានេះមានអ្នកចូលរួមសរុបចំនួន៥០៧នាក់ ស្រី២៧៩នាក់។

**លទ្ធផលទី៦**: *ផែនការសកម្មភាព និងថវិការបស់អង្គការសាមគ្គីត្រូវបានអនុវត្តទាន់ពេលវេលា និងមានប្រសិទ្ធិភាពតាមរយៈដំណើរការការឆ្លុះបញ្ចាំង ការត្រួតពិនិត្យតាមបែបចូលរួមតាមត្រីមាសនិងមានរបាយការណ៍ឆ្លុះបញ្ចាំងប្រចាំឆ្នាំ។*

**សកម្មភាពដើម្បីសម្រេចលទ្ធផលទី៦៖**

**៦.១. ការចូលរួមប្រជុំជាមួយបណ្តាញ អង្គការសង្គមស៊ីវិលក្នុងនិងក្រៅតំបន់**

ការចូលរួមប្រជុំជាមួយបណ្តាញ និងសង្គមស៊ីវិលក្នុងនិងក្រៅខេត្តគឺបានចូលរួមជាបន្តបន្ទាប់។ ការប្រជុំទាំងនោះគឺផ្តោតលើការអប់រំ អភិបាលកិច្ច និងការតស៊ូមតិលើការងារធនធានធម្មជាតិ ការងារអប់រំ។ ការប្រជុំនេះបានផ្តល់

ចំណេះដឹង និងបទពិសោធន៍យ៉ាងច្រើន ជាពិសេសគឺការងារអប់រំ ការការពារធនធានធម្មជាតិ អភិបាលកិច្ចនិងសភាពការណ៍ទូទៅនៅក្នុងពេលបច្ចុប្បន្នដែលមានការចែករំលែករវាងសមាជិករបស់បណ្តាញទាំងនោះ។

**៦.២. ការអភិវឌ្ឍសមត្ថភាពបុគ្គលិកអង្គការសាមគ្គី:** បុគ្គលិក០១នាក់ ត្រូវបានបញ្ជូនឲ្យចូលរួមវគ្គបណ្តុះបណ្តាលខ្លីមួយស្តីពីឧបករណ៍តាមដាន និងវាយតម្លៃគម្រោង និងកម្មវិធីជាមួយវិទ្យាស្ថានអភិវឌ្ឍវិស័យអប់រំ (EDI)ភ្នំពេញ កាលពីថ្ងៃទី២៦-២៧ ខែវិច្ឆិកា ឆ្នាំ២០១៦។

### ៦.៣. ត្រួតពិនិត្យវាយតម្លៃបញ្ចប់គម្រោង

ដើម្បីកំណត់ពីប្រសិទ្ធភាព ផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាន ព្រមទាំងអនុសាសន៍លើការអនុវត្តគម្រោងកម្មវិធីដោយផ្អែកលើសិទ្ធិជាមូលដ្ឋាន១០ឆ្នាំកន្លងមក អង្គការសាមគ្គីបានជួលទីប្រឹក្សាឯករាជ្យ ដើម្បីអនុវត្តការត្រួតពិនិត្យវាយតម្លៃគម្រោងនេះនៅចុងឆ្នាំ២០១៦។ (របាយការណ៍វាយតម្លៃបញ្ចប់គម្រោងរយៈពេល១០ឆ្នាំ) ។

### ៦.៤. សិក្ខាសាលាចែករំលែករបាយការណ៍ឆ្នាំ២០១៥ និងផែនការឆ្នាំ២០១៦ដល់អ្នកពាក់ព័ន្ធ

ក្រុមប្រឹក្សាឃុំ មេភូមិ គណៈកម្មការសហគមន៍នេសាទ គណៈកម្មការតាកុត ជនបង្គោល កសិករគំរូ និងកសិករពង្រីកសរុប ៣៨នាក់ ស្រី ២៤នាក់ បានចូលរួមសិក្ខាសាលាចែករំលែកពីរបាយការណ៍ឆ្នាំ២០១៥ និងផែនការបន្តឆ្នាំ២០១៦របស់អង្គការសាមគ្គី។ សិក្ខាសាលានេះ ដើម្បីផ្តល់ឱកាសឲ្យអ្នកចូលរួមបានចែករំលែកព័ត៌មាន និងផ្ទៀងផ្ទាត់សកម្មភាពនានាដែលបានអនុវត្តក្នុងឆ្នាំ២០១៥។ ជាមួយគ្នានេះផែនការឆ្នាំ២០១៦របស់អង្គការសាមគ្គីត្រូវបានបង្ហាញដោយលំអិត និងបានចែករំលែកជាឯកសារផែនការទាំងមូលដល់អ្នកចូលរួមគ្រប់ៗគ្នា។ តំណាងក្រុមប្រឹក្សាឃុំគោលដៅទាំង២(ឃុំមៀន និងត្រពាំងព្រះ)បានសាទរចំពោះលទ្ធផល ហើយគាត់បានសំណូមពរដល់ក្រុមគោលដៅចូលរួមអោយបានកាន់តែសកម្មថែមទៀតជាមួយអង្គការសាមគ្គីដើម្បីអភិវឌ្ឍន៍សហគមន៍ភូមិឃុំអោយកាន់តែរីកចំរើន។

### ៦.៥. ការត្រួតពិនិត្យយ៉ាងទូលំទូលាយ/ដំណើរការការឆ្លុះបញ្ចាំងនិងត្រួតពិនិត្យតាមបែបចូលរួម

ឆ្នាំ២០១៦នេះ ដំណើរការឆ្លុះបញ្ចាំងនេះត្រូវបានរៀបចំ១លើក ដែលមានការចូលរួមពីជនបង្គោល កសិករគម្រូ កសិករពង្រីក មេភូមិ គណៈកម្មការប្រើប្រាស់ទឹកតាកុត សហគមន៍បឹងកេះ និងទំនប់ថ្មដំរីសរុបចំនួន២៤នាក់ស្រី១៣នាក់។ ការឆ្លុះបញ្ចាំងនេះបានផ្តោតលើដំណើរការ និងលទ្ធផលរបស់អង្គការសាមគ្គី។ ក្រោយពីកិច្ចពិភាក្សាតាមក្រុមយើងរកឃើញថា អង្គការសាមគ្គីបានអនុវត្តការងារទទួលបានជោគជ័យច្រើន។ ប៉ុន្តែក៏មានចំណុចខ្វះខាត និងចំណុចត្រូវកែលំអមួយចំនួនផងដែរ។ សាមគ្គីនឹងត្រូវរៀបចំការប្រជុំឆ្លុះបញ្ចាំងនេះសារថ្មីឲ្យបានទៀងទាត់ ដើម្បីវិភាគនូវចំនុចខ្វះដែលរកឃើញ និងវិភាគរកដំណោះស្រាយថាតើត្រូវមានវិធីសាស្រ្ត និងដំណោះស្រាយដូចម្តេច។

## ៣. ការផ្លាស់ប្តូរសំខាន់ៗ

តាមរយៈបទអន្តរាគមន៍ឆ្នាំ២០១៦នេះ ឃើញថា មានការផ្លាស់ប្រែជាវិជ្ជមានគួរឲ្យកត់សំគាល់លើការរស់នៅប្រចាំថ្ងៃរបស់ក្រុមគោលដៅ។ ពួកគាត់មានការយល់ដឹងពីសិទ្ធិជាមូលដ្ឋាន ដែលធ្វើឲ្យគាត់មានសេចក្តីក្លាហាន ហ៊ានលើកឡើងនូវសំនួរ និងកង្វល់របស់គាត់ទៅកាន់អាជ្ញាធរពាក់ព័ន្ធ(Supply Sides)ដោយមិនញញើតនោះទេ។ ជាពិសេសគឺការតស៊ូមតិលើផ្នែកអប់រំ និងការការពារធនធានធម្មជាតិក្នុងសហគមន៍។ ជាក់ស្តែងនៅរដូវបិទនេសាទកន្លងមក គណៈកម្មការសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋបាននាំគ្នាល្បាត និងបង្ក្រាបបទល្មើសនេសាទនៅជុំវិញបឹងធំយ៉ាងសកម្ម។ សកម្មភាពនេះក៏មានការសហការជាមួយសមត្ថកិច្ចរដ្ឋបាលជលផល និងនគរបាលឃុំផងដែរ

ដើម្បីសុវត្ថិភាព និងប្រសិទ្ធភាព។ សរុបមកចំណេះដឹងពីការតស៊ូមតិរួមនឹងឆន្ទៈផ្ទាល់ខ្លួនរបស់សហគមន៍ផងនោះ បានធ្វើឲ្យការអនុវត្តសកម្មភាពរបស់យើងទទួលបានផលប្រកបដោយប្រសិទ្ធភាព។

**ផ្នែកចិញ្ចឹមជីវិត** (Livelihood/ Food Security)៖ សង្កេតឃើញថា ការគាំទ្រលើផ្នែកបណ្តុះបណ្តាលពង្រឹងបច្ចេកទេស និងតាមដានការអនុវត្តន៍គឺជាមធ្យោបាយមួយ ដែលជំរុញឲ្យការងារកសិកម្មអាចដំណើរការបាន។ ឆ្នាំ២០១៦នេះឃើញថា មានការរីកចំរើនតិចតួច ព្រោះថាមានកសិករមួយចំនួនបានយកចិត្តទុកដាក់ ព្យាយាមអនុវត្ត ដោយពុំបានទុកពេលវេលាចោលឡើយ បើទោះឆ្នាំនេះជួបបញ្ហារាំងស្ងួត ខ្វះទឹកស្រោច ជម្ងឺសត្វ សត្វល្អិតបំផ្លាញដំណាំ និងចុងឆ្នាំមានភ្លៀងធ្លាក់ជោគជាំយ៉ាងណាក៏ដោយ។

**ផ្នែកកម្មវិធីគាំពារកុមារ និងការអប់រំ** (Child Sponsorship & Education)៖ បុគ្គលិកគាំពារកុមារបានយកចិត្តទុកដាក់ខ្លាំង ជាពិសេសសំរិតសំរាំងគុណភាពសារ និងការតាមដានពីស្ថានភាពកុមារយ៉ាងទៀងទាត់។ ជាងនេះទៅទៀត អាណាព្យាបាល អាជ្ញាធរភូមិ មានការយកចិត្តទុកដាក់ចូលរួមក្នុងកម្មវិធីគាំពារកុមារយ៉ាងសកម្មដូចជា កម្មវិធីប្រមូលសារ ការរៀបចំមុនប្រមូលសារ។ តាមរយៈវេទិកាស្តីពីការអភិវឌ្ឍបរិស្ថានសាលារៀនដែលគាំទ្រដោយអង្គការ NEP ឃើញថាភាគីពាក់ព័ន្ធមានការចូលរួមផ្សព្វផ្សាយយ៉ាងសកម្មពីសារៈសំខាន់នៃការអប់រំ។ លើសពីនេះទៀត តំណាងក្លឹបកុមារដែលបានចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំបានចែករំលែកពត៌មានជាច្រើនដល់សមាជិករបស់ក្លឹបរបស់ពួកគេ។

**ផ្នែកធនធានធម្មជាតិ** (Natural Resource)៖ សង្កេតឃើញថា គណៈកម្មការសហគមន៍នេសាទសាមគ្គីឃុំមៀន អាជ្ញាធរមូលដ្ឋាន មេភូមិ សមត្ថកិច្ច រដ្ឋបាលជលផល និងប្រជាពលរដ្ឋ មានការចូលរួមយ៉ាងសកម្ម ពិសេសក្នុងសកម្មភាពល្បាត និងបង្ក្រាបបទល្មើសនេសាទនៅជុំវិញដែនសហគមន៍នេសាទ។ ការចូលរួមនេះគឺជាចំណុចគួរកត់សំគាល់ ព្រោះថាគាត់បានយល់ដឹងពីសិទ្ធិ និងកាតព្វកិច្ចក្នុងការពារធនធានសហគមន៍របស់ខ្លួន។ ឆ្នាំនេះគឺមានទាំងសប្បុរសជន ប្រជាពលរដ្ឋចូលរួមជាកំលាំងកាយ ថវិកា ទឹកសុទ្ធ និងសាំងជាដើមសំរាប់សកម្មភាពល្បាត បង្ក្រាបបទល្មើសនេសាទ។ ប៉ុន្តែនៅរដូវបើកនេសាទចុងឆ្នាំ(ត្រីមាសទី៤)បទល្មើសនេសាទបានកើតឡើងវិញដដែល ព្រោះមានការឃុំខិតរវាងជនល្មើស និងមន្ត្រីខិលខូចមួយចំនួនលបលួចប្រព្រឹត្តិមិនពិចារណារធនធានឡើយ។

### ៤. បញ្ហាប្រឈម ឬ ឧបសគ្គ:

ឆ្នាំ២០១៦នេះ ថ្វីត្បិតតែសកម្មភាពភាគច្រើនត្រូវបានអនុវត្តក៏ដោយ ប៉ុន្តែមានសកម្មភាពមួយចំនួនមិនត្រូវបានអនុវត្តទៅតាមផែនការប្រចាំឆ្នាំនោះទេ។ បញ្ហាប្រឈម៖ ១/ផ្នែកកសិកម្ម: ភាពរាំងស្ងួតហួតហែងខ្លាំបំផុត ខ្វះទឹកស្រោចស្រពដំណាំ សត្វល្អិតបំផ្លាញ សត្វមានជម្ងឺ កន្លែងខ្លះខ្វះទឹកប្រើប្រាស់ ហើយកសិករចំណាកស្រុក។ ២/ កម្មវិធីគាំពារកុមារៈ កុមារមួយចំនួនចំណាកស្រុក ទៅបួសជាព្រះសង្ឃ រៀបការ និងមានអាយុច្រើន ហើយមួយចំនួនត្រូវបានម្ចាស់ឧបត្ថម្ភបញ្ឈប់ការគាំទ្រនាំឲ្យថវិកាគម្រោងថយចុះជាលំដាប់។ អាណាព្យាបាលមួយចំនួនមិនចង់ឲ្យកុមារចូលរួមក្នុងសកម្មភាពគូសារ ឬថតរូបឡើយ។ ៣/ផ្នែកធនធានធម្មជាតិ (សហគមន៍នេសាទ) គណៈកម្មការសហគមន៍រងការគំរាមគំហែងពីជនល្មើស។ បទល្មើសនេសាទ ពិសេសអួនស្បៃម៉ុង សៃ ការឃុំឃិតរវាងជនល្មើស និងមន្ត្រីខិលខូចមួយចំនួននៅតែកើតមាន។ គម្រោងនឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០១៦ ហើយមិនទាន់មានការគាំទ្រពីម្ចាស់ជំនួយផ្សេងឡើយ។

## ៥. ការគ្រប់គ្រងធនធានមនុស្សនៅក្នុងអង្គការ

**ការប្រជុំ និងការពង្រឹងសមត្ថភាពបុគ្គលិក**៖ ធនធានមនុស្សជាគន្លឹះសំខាន់ដើម្បីឈានទៅជោគជ័យការងារក្នុងអង្គភាពមួយ។ ឆ្នាំ២០១៦នេះ បុគ្គលិកសាមគ្គីកំពង់ចាមបានចូលរួមប្រជុំក្រុមប្រឹក្សានាយកចំនួន៣លើក។ កិច្ចប្រជុំនេះ

ត្រួតពិនិត្យកែលំអលើការងាររបស់អង្គការសាមគ្គី និងធ្វើបច្ចុប្បន្នភាពលើគោលការណ៍សំខាន់ៗរបស់សាមគ្គី។ ទន្ទឹមនឹងនេះ សាមគ្គីបានប្រជុំគណៈកម្មការគ្រប់គ្រង និងក្រុមការងារជាប្រចាំដើម្បីត្រួតពិនិត្យលទ្ធផលការងារ ការតំរង់ទិសការងារ និងដោះស្រាយបញ្ហានានាដែលជួបប្រទះ។ សាមគ្គីក៏បានពង្រឹងសមត្ថភាពដល់បុគ្គលិកតាមរយៈការចូលរួមវគ្គខ្លីស្ដីពីឧបករណ៍តាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោងកម្មវិធីចំនួន១នាក់)។

ឆ្នាំ២០១៦នេះ បុគ្គលិកសុំច្បាប់ឈប់សំរាកចំនួន......លើក ស្មើនឹង.....ថ្ងៃ ដោយសារមានធុរៈផ្ទាល់ខ្លួន និងបញ្ហាសុខភាព។ បុគ្គលិកស្ម័គ្រចិត្ត (លោក ផាត ម៉ារី)បានលាឈប់ពីការងារ ដោយមូលហេតុជួយការងារឪពុកម្ដាយនៅផ្ទះ ហើយយើងបានជ្រើសអ្នកស្ម័គ្រចិត្តម្នាក់(កញ្ញា លីន ស៊ាងហៃ)ដើម្បីជំនួស។

**បញ្ជីរាយនាមបុគ្គលិកក្នុងឆ្នាំ២០១៦**

| ល.រ | ឈ្មោះ | តួនាទី | ភេទ | ទូរសព្ទ | អ៊ីម៉ែល |
|---|---|---|---|---|---|
| ១ | អ៊ុក អាំងគីម | នាយកប្រតិបត្តិ | ប | ០១៧ ៨២០ ១៩០ | samakyngo@gmail.com |
| ២ | ស៊ីម ហុន | អ្នកសំរបសំរួល | ប | ០១២ ៥៩៩ ៧៨៥ | simkimhun@yahoo.com |
| ៣ | លឹម ឈុនអេង | គាំពារកុមារ | ស | ០៩២ ៤៥២ ៥៦០ | chhunengl@yahoo.com |
| ៤ | ណាំ ស្រីណាវ | ជំនួយការ | ស | ០៩៨ ៨១៨ ៦២៩ | namsreynav@gmail.com |
| ៥ | វ៉ាន់ ស៊ីណេត | រដ្ឋ/ ហិរញ្ញវត្ថុ | ស | ០៦៩ ៧៤០ ៧២៩ | vannsinet@gmail.com |
| ៦ | លីន ស៊ាងហៃ | អ្នកស្ម័គ្រចិត្ត | ស | ០៩៦ ៤៥ ៨៣ ៦៤៤ | linseanghai@gmail.com |

## ៦. ករណីសិក្សាពីការផ្លាស់ប្ដូរ

ឆ្នាំ២០១៦នេះ អង្គការសាមគ្គីបានគាំទ្រសកម្មភាពឆ្លុះបញ្ចាំងរវាងកសិករអោយមានការផ្លាស់ប្ដូរបទពិសោធន៍រវាងកសិករ និងកសិករលើការងារកសិកម្មនិរន្តរភាព។ យើងសង្កេតឃើញថា ជីវភាពកសិករមួយចំនួនមានការផ្លាស់ប្ដូរជាវិជ្ជមាន។ ខាងក្រោមនេះជាករណីសិក្សាខ្លីៗ ដែលបង្ហាញពីការផ្លាស់ប្ដូរលើឥរិយាបទ និងជីវភាពរស់នៅរបស់កសិករក្រុមគោលដៅដែលប្រើប្រាស់ធារាសាស្ត្រតាកុត និងកម្មវិធីគាំពារកុមារ និងការអប់រំ។ ករណីសិក្សាទាំងនេះក៏ត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍បញ្ចប់គម្រោងផ្នែកគាំពារកុមារផងដែរ។

### ធារាសាស្ត្រតាកុតបានផ្ដល់ក្ដីសង្ឃឹមដល់កសិករភូមិយើង

ប្រព័ន្ធធារាសាស្ត្រតាកុតត្រូវបានជួសជុល ស្ដារឡើងវិញដោយជោគជ័យ បន្ទាប់ពីអង្គការអាក់សិនអេតនិងអង្គការសាមគ្គីបានគៀងគរប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានពិភាក្សាពីដំណើរការស្វែងរកបដិភាគសំរាប់គម្រោងជួសជុល និងស្ដារទំនប់ប្រឡាយនៅតំបន់នេះ។ មុនជួសជុលដីស្រែជាច្រើនហិកតា ដែលត្រូវបានទុកចោលជាច្រើនឆ្នាំ។ ប៉ុន្តែអ្វីៗបានផ្លាស់ប្ដូរក្រោយពីការជយសជុលរួចរាល់។ ប្រជាជនជាច្រើនគ្រួសារបានវិលមក ចិញ្ចឹមជីវិតដោយធ្វើស្រែពឹងផ្អែកលើទឹកអាងតាកុតនេះ។ បញ្ហាកង្វះខាតស្បៀងអាហាររបស់ប្រជាជនត្រូវបានកាត់បន្ថយ។

បងស្រីសំ ទីនជាកសិកររស់នៅភូមិកេះម្នាក់បានរៀបរាប់ប្រាប់យើងថា *″កាលពីមុនខ្ញុំតែងតែប្រឈមនឹងបញ្ហាកង្វះស្បៀងរយៈពេលពី៣ទៅ៦ខែជារៀងរាល់ឆ្នាំ។ ខ្ញុំតែងតែធ្វើចំណាកស្រុកទៅធ្វើការនៅចំការដំឡូងមីនៅខេត្តផ្សេងដើម្បីរកប្រាក់ចំណូល។ កូនរបស់ខ្ញុំពីរនាក់ពុំដែលបាននៅរៀនសូត្រជាប់លាប់នោះទេព្រោះត្រូវជួយធ្វើការងារខ្ញុំ។ ប៉ុន្តែឥឡូវនេះ ស្រែប្រាំងរបស់ខ្ញុំដំណើរការបានល្អហើយមិនខ្វះខាតប្រឡាយទឹកស្រោចស្រពទៀតទេ។ កូនៗរបស់ខ្ញុំបានទៅសាលារៀនសូត្រ ហើយមានអាហារហូបគ្រប់គ្រាន់។ ខ្ញុំពិតជារីករាយ និងសូមអរគុណខ្លាំងណាស់ ចំពោះអង្គការសាមគ្គី និអាក់សិនអេត ដែលបាននាំមកនូវការផ្លាស់ប្តូរផ្នែកជីវភាពរស់នៅសំរាប់ខ្ញុំ និងប្រជាជនឲ្យប្រសើរជាងមុន។ ឥឡូវនេះ ទិន្នផលស្រូវរបស់ខ្ញុំមានការកើនឡើងជាងមុន ដោយសារតែមានទឹក ប្រឡាយគ្រប់គ្រាន់ធ្វើឲ្យស្រូវទទួលបានផលល្អ មិនស្កកដូចពីមុនទេ។ កាលពីមុនគឺ១ហិកតាបានត្រឹមតែ១តោនប៉ុណ្ណោះ តែឥឡូវ១ហិកតាទទួលបានពី៣ទៅ៤តោន។ ខ្ញុំរំពឹងថា ខ្ញុំនឹងអ្នកភូមិដទៃទៀតបានធ្វើស្រែរហូត និងលែងខ្វះខាតស្បៀងទៀតហើយ ចំណែកកូនៗរបស់ខ្ញុំ(កុមារីផល ចាន់ឌឿនរៀនថ្នាក់ទី៨)ក៏បានទៅរៀនទៀងទាត់មិនចំណាកស្រុកខ្ញុំដូចកាលពីមុននោះទេ″*។ ជាងនេះទៅទៀត បងស្រីបានប្រាប់ថាក្នុងសហគមន៍របស់គាត់មានការផ្លាស់ប្តូរជីវភាពល្អប្រសើរមានស្បៀងហូបគ្រាប់គ្រាន់ កាត់បន្ថយការចំណាកស្រុក និងអាចផ្គត់ផ្គង់អោយកូនៗបានចូលរៀនទៀងទាត់។ ធារាសាស្រ្តតាកុតពិតជាបានផ្តល់ក្តីសង្ឃឹមមិនចេះសាបសូន្យដល់កសិករយ៉ាងពិតប្រាកដ។ ព្រោះថាពួកគាត់មានទឹកគ្រាប់គ្រាន់ក្នុងការបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀត។ អ្នកភូមិផ្សេងទៀតមានអាម្មណ៍រីករាយណាស់ចំពោះសកម្មភាពកសិកម្ម និងការសិក្សារបស់កូនៗដែលបានរៀនទៀងទាត់។ ម្តាយឪពុកបានងាកមករក និងចាប់អារម្មណ៍ពីសារៈសំខាន់នៃការអប់រំ ដែលអង្គការសាមគ្គីធ្លាប់បានផ្សព្វផ្សាយកន្លងមក និងធ្វើយុទ្ធនាការជំរុញអោយមាតាបិតា ដែលមានកូនគ្រប់អាយុអោយមកចុះឈ្មោះចូលរៀនគឺដោយសារតែគាត់មានជីវភាពប្រសើរ ដែលមានលទ្ធភាពបញ្ជូនកូនទៅសាលារៀន។





*ចំណែកអ្នកធ្វើស្រែនៅប៉ែកខាងលិចបឹងកេះឯណោះវិញ ដោយសារតែទឹកស្រោចស្រពមិនគ្រប់គ្រាន់ ពួកគាត់បានទុកដីស្រែចោល ហើយចំណាកស្រុកទៅធ្វើការរកប្រាក់ចំណូលផងដែរ។ ដោយឃើញបញ្ហាខាងលើ អង្គការសាមគ្គីបានគាំទ្រការជីកអណ្តូងទឹកចំនួន៥ដើម្បីស្រោចស្រង់ស្រែប្រាំងទាំនោះពីការស្ងួតក។ អណ្តូងទាំងនេះអាចស្រោចស្រពផ្ទៃដីជាង៣៥ហិតានៅជុំវិញនោះ ដែលមានអ្នកទទួលផល៨៩គ្រួសារស្មើនឹង៥៣៤នាក់។ ឥឡូវនេះពួកគេមានភាពសប្បាយរីករាយដែលមានទឹកនៅជិតស្រែបានស្រោចស្រពគ្រប់គ្រាន់ទាំងរដូវប្រាំង និងរដូវវស្សា។ បងស្រីងាន់ ស្រីអនអាយុ៣៥ឆ្នាំ រស់នៅភូមិអូរសង្កែបាននិយាយថា″* ខ្ញុំពិតជាសប្បាយរីករាយណាស់ដែលមានប្រភពទឹកនៅជិតស្រែរបស់ខ្ញុំ។ វាធ្វើអោយផលស្រូវរបស់ខ្ញុំមានការកើនឡើងជាងមុន″។

**ក្លឹបកុមារជាកន្លែងរៀនសូត្រយ៉ាងសំខាន់**



កុមារីញិល ម៉ារីអាយុ១៤ឆ្នាំរស់នៅភូមិអូរដូនញា ឃុំត្រពាំងព្រះ។នាងជាកូនទី២ក្នុងចំណោមបងប្អូន៣នាក់ ស្រីទាំងបី។ ម៉ារីរៀនថ្នាក់ទី៧នៃអនុវិទ្យាល័យកោះតាភេម។ ម៉ារីជាសមាជិកក្នុងក្លឹបនេះបាននិយាយថា *″ខ្ញុំមានអារម្មណ៍សប្បាយរីករាយដែលបានចូលរួមក្នុងក្លឹបកុមារដែលអង្គការសាមគ្គីនិងអាក់សិនអេតបានរៀបចំឡើងក្នុងភូមិរបស់ខ្ញុំ។ ខ្ញុំមកទីនេះជារៀងរាល់ថ្ងៃអាទិត្យនិងថ្ងៃឈប់សំរាក។ ខ្ញុំទទួលបានចំនេះដឹងជាច្រើនពីការអនាម័យខ្លួនប្រាណសិទ្ធិកុមារភាពជាអ្នកដឹកនាំនិងគំនិតច្នៃប្រឌិតនៃការគូរូប ។ ចំណែកការសិក្សារបស់ខ្ញុំឆ្នាំនេះដំណើរការល្អហើយមុខវិជ្ជាដែលខ្ញុំចូលចិត្តជាងគេគឺអក្សរសាស្ត្រខ្មែរ។ ថ្ងៃអនាគតខ្ញុំចង់ ធ្វើជាគ្រូបង្រៀនដ៏ល្អម្នាក់នៅក្នុងភូមិរបស់ខ្ញុំ″។* សាមគ្គីនិងអាក់សិនអេត បានបង្កើតក្លឹបកុមារចំនួន១២ភូមិ(មានសមាជិសរុប៣៦៥នាក់ស្រី១៥៨នាក់)ក្នុងភូមិគោលដៅ។ ក្លឹបនេះបង្កើតឡើងដើម្បីអោយកុមារបានជួបជុំលេងកំសាន្តនិងជុំរុញលើកទឹកចិត្តអោយកុមារខិតខំរៀនសូត្រ។ ក្លឹបនេះបានក្លាយជាកន្លែងដែលកុមារចូលចិត្តចូលមករៀនសូត្រនៅពេលទំនេរពីការសិក្សា។ ដោយទឹកមុខរីករាយម៉ារីថា *″ការចូលរួមក្លឹបកុមារនេះធ្វើអោយខ្ញុំមានសមត្ថភាព និងទទួលបានចំនេះដឹងច្រើនពីបងៗ។ ខ្ញុំសូមអរគុណដល់អង្គការសាមគ្គី និងអាក់សិនអេតដែលបានបង្កើតក្លឹបកុមារក្នុងភូមិរបស់ខ្ញុំ។ សូមជូនពរអោយអ្នកមានសុខភាពល្អ។ ខ្ញុំមានអារម្មណ៍ថាខ្ញុំពិតជាមានការផ្លាស់ប្តូរពីព្រោះថាឥឡូវខ្ញុំហ៊ាននិយាយជាមួយក្រុមកុមារភាពដោយមិនមានការភ័យខ្លាចដូចមុនទេ″។* អ្វីដែលខុសប្លែកគួរអោយកត់សំគាល់នោះគឺការ

កុមារមានទំលាប់អនាម័យខ្លួនប្រាណ យល់ដឹងពីសិទ្ធិកុមារ ភាពជាអ្នកដឹកនាំ និងគំនិតច្នៃប្រឌិតរូបគំនូររបស់ខ្លួន។ ការផ្លាស់ប្តូរជាវិជ្ជមានរបស់ម៉ារីគឺនាងឧស្សាព្យាយាមរៀនសូត្រ មានភាពក្លាហានហ៊ាននិយាយជាមួយក្រុមកុមារដោយក្លាហានបំផុត និងមានទំលាប់លាងដៃជាប្រចាំមុន និងកាន់ចំណីអាហារ។

## ការគាំទ្រសំភារៈសិក្សាគឺជាចំណែកមួយលើកទឹកចិត្តដល់កុមារក្រីក្រក្នុងការរៀនសូត្រ

ការអប់រំមានសារៈសំខាន់ណាស់ចំពោះកុមារ។ កុមារមួយចំនួននៅក្នុងភូមិគោលដៅពុំបានទៅរៀនសូត្រជាទៀងទាត់នោះទេ ដោយសារតែកត្តាជីវភាពគ្រួសារក្រីក្រ និងការយល់ដឹងរបស់ឪពុកម្តាយពីសារៈសំខាន់នៃការអប់រំនៅមានកំរិត ដែលនាំអោយគាត់ទាញយកកុមារអោយជួយរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ ក្រោយពីមានការអន្តរាគមន៍របស់សាមគ្គី និងអាក់សិនអេតលើផ្នែកអប់រំ និងការលើកស្ទួយចិញ្ចឹមជីវិតតាមរយៈការគាំទ្រសំភារៈសិក្សាកុមារ និងសកម្មភាពកសិកម្ម ឃើញថាពួកគាត់មានជីវភាពប្រសើរជាងមុន។ ដោយទឹកមុខរីករាយកុមារី ចន ចាន់ឌឿន មានអាយុ១៤ឆ្នាំរស់នៅភូមិកេះ ឃុំមៀនបាននិយាយថា *"ខ្ញុំសប្បាយចិត្តណាស់ដែលទទួលបានសម្ភារៈសិក្សា ហើយ និងឯកសណ្ឋានគ្រប់គ្រាន់។ ក៏ប៉ុន្តែពីមុនឪពុកម្តាយរបស់ខ្ញុំពុំមានលទ្ធភាពផ្តល់នូវសម្ភារៈទាំងនោះអោយខ្ញុំនោះទេ។ ឥឡូវ ខ្ញុំសប្បាយរីករាយណាស់ ដែល អង្គការសាមគ្គីបានផ្តល់សម្ភារៈសិក្សាដូចជា សៀវភៅ ប៊ិច ខ្មៅដៃ និងសំល្លៀកបំពាក់សិក្សាដល់ខ្ញុំ*។ សម្ភារៈទាំងនេះពិតជាសំខាន់សំរាប់សិស្សពេលចូលរៀន។ ចាន់ឌឿនជាកូនទី៤ក្នុងចំណោមបងប្អូន៤នាក់ស្រី២នាក់។ឪពុកម្តាយចាន់ ឌឿនជាកសិករម្នាក់ដែលប្រកបមុខរបរធ្វើស្រែប្រាំងតែមួយគត់។ ប្រាក់ចំណូលបានបន្តិចបន្តួចពុំអាចផ្គត់ផ្គង់ សូម្បីតែអាហារប្រចាំថ្ងៃ ដូច្នេះបញ្ហាប្រាក់ចំណូលគឺជាបញ្ហាអាទិភាពនៃគ្រួសាររបស់ពួកគាត់។ ចាន់ ឌឿនបានបន្តទៀតថា *"ជួនកាលឪពុកម្តាយរបស់ខ្ញុំ បានជុំរុញអោយខ្ញុំមិនទៅសាលារៀនទេ គឺអោយខ្ញុំជួយរកចំណូល និងជួយធ្វើការងារផ្ទះ*។ ចាន់ឌឿនស៊ីឈ្នួលដកស្ទូង និងបេះសណ្តែកដើម្បីជួយរកចំណូល។ ជាងនេះទៅទៀត ចាន់ឌឿនបានជួយការងារផ្ទះដូចជាដងទឹក ដាំបាយ ចំអិនម្ហូប អោយចំណីជ្រូក ស្រោចទឹកត្រសក់ ជំរាសស្មៅ និងមើលគោ។ ចាន់ ឌឿនក៏បញ្ជាក់ទៀតថាដោយសារតែគ្មានការលើកទឹកចិត្តពីឪពុកម្តាយរបស់នាង និងបញ្ហាគ្រួសារផងនោះ ធ្វើអោយចាន់ ឌឿនទៅរៀនមិនបានទៀងទាត់ លទ្ធផលសិក្សារបស់នាងខ្សោយរៀនមិនទាន់គេ ដែលធ្វើអោយនាងខ្មាសមិត្តភក្តិស្ទើរតែឈប់រៀនទៅហើយ។



## ៧. ការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ

យោងកិច្ចព្រមព្រៀង(MOU)រវាងអង្គការអាក់សិនអេតកម្ពុជា និងអង្គការសាមគ្គីឆ្នាំ២០១៦ អង្គការសាមគ្គីត្រូវទទួលបានការគាំទ្រថវិកាប្រចាំឆ្នាំចំនួន ៣៧,១៤៦.១០ដុល្លារពីអង្គការអាក់សិនអេតកម្ពុជា សម្រាប់ដំណើរការកម្មវិធីអភិវឌ្ឍន៍តំបន់ដែលផ្តោតលើកម្មវិធីសិទ្ធិជាមូលដ្ឋាន(LRP)។ ឆ្នាំ២០១៦នេះ សាមគ្គីបានចំណាយថវិកាអស់ចំនួន ៣៣,៩០២.៩៣ ដុល្លារតែប៉ុណ្ណោះលើដំណើរការប្រតិបត្តិការទាំងមូល ហើយនៅសល់ថវិកាចំនួន ៣,២៤៣.១៧ ដុល្លារដែលត្រូវបង្វិលត្រឡប់ទៅអង្គការអាក់សិនអេតកម្ពុជាវិញ។

## ៨. ការគ្រប់គ្រងផ្នែកគាំពារកុមារ

កម្មវិធីគាំពារកុមារ ជាកម្មវិធីចំបងរបស់អង្គការសាមគ្គីដើម្បីស្វែងរកថវិកាទ្រទ្រង់ដំណើរការអភិវឌ្ឍន៍សហគមន៍ទាំងមូល។ ផ្នែកនេះមានសកម្មភាពជាច្រើនជាមួយកុមាររួមមានការអប់រំកុមារពីអនាម័យនៃការរស់នៅ កម្មវិធីសប្បាយៗ ការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ការជួបជុំគ្នាប្រចាំត្រីមាស និងកម្មវធីប្រមូលសារកុមារ។ ដើមឆ្នាំ២០១៦ កុមារគូសារមានម្ចាស់ឧបត្ថម្ភមានចំនួន២៦៥ស្រី១៤២នាក់។ ការប្រមូលលើកទី១ ទទួលបានចំនួន២៥០នាក់ លើកទី២ ប្រមូលសារបានចំនួន២២២នាក់។ ចំណែកកុមារ៣៣នាក់ផ្សេងទៀតត្រូវបានផ្តាច់ការឧបត្ថម្ភដោយមូលហេតុកុមារមានអាយុច្រើន រៀបការ បួសជាព្រះសង្ឃ កុមារចំណាកស្រុក និងដោយមូលហេតុម្ចាស់ឧបត្ថម្ភផ្តាល់។ ការប្រមូលសារ និងការបញ្ជ្រាបកម្មវិធីគាំពារកុមារនេះមានការចូលរួមពីជនបង្គោល មេភូមិ តំណាងក្លឹប ឪពុកម្តាយ និងអាណាព្យាបាល។ សកម្មភាពនេះអាចប្រព្រឹត្តិទៅយ៉ាងរលូនគឺដោយសារតែមានកិច្ចសហការរវាងបុគ្គលិក អ្នកស្ម័គ្រចិត្ត តំណាងក្លឹបកុមារ និងជនបង្គោល ដែលលះបង់ពេលវេលា កំឡាំងកាយ ចិត្តព្យាយាមទំនាក់ទំនងកៀងគរក្នុងសកម្មភាពប្រមូលសារពិសេសពេលមានពិធីបុណ្យធំៗ ដូចជាចូលឆ្នាំខ្មែរនិងបុណ្យភ្ជុំបិណ្ឌជាដើម ជាឱកាសដែលកុមារវិលត្រឡប់ពីការចំណាកស្រុក។ របាយការណ៍រីកចម្រើន ព្រឹត្តិបត្រសហគមន៍ និងរបាយការបញ្ចប់គម្រោងគាំពារកុមារត្រូវបានរៀបចំនិងផ្ញើជូនអង្គការអាក់សិនអេតតាមផែនការគ្រោងទុក។

## ៩. សេចក្តីសន្និដ្ឋាន

ផ្អែកតាមសកម្មភាពអន្តរាគមន៍ឆ្នាំ២០១៦នេះ យើងអាចសន្និដ្ឋានបានថា សហគមន៍ក្រុមគោលដៅមានការចូលរួមយ៉ាងសកម្មទាំងផ្នែកសិទ្ធិទទួលបានចំណីអាហារ (Food Rights) ទាំងផ្នែកគាំពារកុមារនិងការអប់រំ(Child sponsorship &Education)ព្រមទាំងការគ្រប់គ្រងធនធានធម្មជាតិ(Natural Resource Management)នៅក្នុងសហគមន៍មានការរីកចម្រើន និងផ្លាស់ប្តូរជាវិជ្ជមាន។ ចំណែកកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចជំនាញ និងស្ថាប័នពាក់ព័ន្ធក៏មានដំណើរការល្អប្រសើរផងដែរ។

ដីក្រហម, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

**អ្នកសម្របសម្រួល**

បានឃើញ និងឯកភាព

**នាយកប្រតិបត្តិ**

**អ៊ុក អាំងគីម**

**ស៊ឹម ហុន**